# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

ថ្ងៃអង្គារ ១២ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី «ការបញ្ចប់ដំណើរការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀន ឯកទេសអប់រំកាយ និងកីឡា»

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការជាគ្រូបង្រៀនឱ្យបម្រើការក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សូមជម្រាបជូនសាធារណជនជ្រាបថា ដំណើរការនៃការប្រឡងប្រជែងជ្រើសរើស គ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា បានបញ្ចប់ដោយជោគជ័យ នារសៀលថ្ងៃចន្ទ ទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤ ប្រកបដោយវិន័យ សណ្តាប់ធ្នាប់ និងសុក្រឹតភាព ស្ថិតក្រោមការតាមដានមើលរបស់អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន ដោយឈរលើគោលការណ៍ គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ។

ដំណើរការប្រឡងវិញ្ញាសាសំណេរ បានប្រព្រឹត្តទៅនាសម័យប្រឡងថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៤ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយមានបេក្ខជនប្រឡងចំនួន **១៧៤៦ នាក់** និងបេក្ខជនអវត្តមាន **១៤៦ នាក់ (ស្រី៤៦ នាក់)** ហើយដំណើរការកែសន្លឹកកិច្ចការ បានប្រព្រឹត្តទៅនៅមណ្ឌលកំណែសាលាភូមិន្ទរដ្ឋបាល ចាប់ពីព្រឹកថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤។ សម្រាប់ការប្រឡងវិញ្ញាសាអនុវត្តន៍កីឡា បានចាប់ផ្តើមពីរសៀលថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដោយមានបេក្ខជនប្រឡងចំនួន **១៧២៤ នាក់** និងបេក្ខជនអវត្តមាន**១៦៨ នាក់ (ស្រី ៥៣ នាក់)** ។

គណៈកម្មការ បានបូកស្រង់ពិន្ទុដោយធ្វើការរៀបលំដាប់ពិន្ទុពីធំទៅតូច និងតាមទីកន្លែងបំពេញការងារដែលបេក្ខជនបានជ្រើសរើសនៅពេលដាក់ពាក្យប្រឡងប្រជែង។ លទ្ធផលបេក្ខជនជាប់ជាស្ថាពរ ១០០ នាក់ ដោយក្នុងចំណោមនោះៈ កម្រិតបណ្តុះបណ្តាល ១២+២ ចំនួន ៧៥ នាក់ (ស្ត្រី ០៧ នាក់) បែងចែកក្នុងខេត្តចំនួន២០ ក្នុងនោះ ទៅវិទ្យាល័យចំនួន២១ និងអនុវិទ្យាល័យ ៥៤ ទីតាំង និងកម្រិតបណ្តុះបណ្តាល ១២+៤ ចំនួន ២៥ នាក់ ( ស្ត្រី ០១ នាក់) បែងចែកក្នុងខេត្តចំនួន១៣ ក្នុងនោះ ទៅវិទ្យាល័យចំនួន១៥ និងអនុវិទ្យាល័យ ១០ ទីតាំង ។ បេក្ខជន ១០០ នាក់ដែលបានជ្រើសរើស គឺសម្រាប់ខេត្តគោលដៅចំនួន ២១ ។ គណៈកម្មការ ក៏បានជ្រើសរើសបេក្ខជនជាប់បម្រុងចំនួន ១០ នាក់ ក្នុង០១ ខេត្ត លើកលែងខេត្តមណ្ឌលគិរី មានបេក្ខជនជាប់បម្រុងចំនួន ០៦ នាក់ និងខេត្តស្ទឹងត្រែងចំនួន ០៨ នាក់។

គណៈកម្មការរៀបចំការប្រឡង បានប្រកាសបញ្ជីលទ្ធផលបេក្ខជនជាប់ជាស្ថាពរ ជាសាធារណៈ តាមគេហទំព័រផ្លូវការរបស់ក្រសួងមុខងារសាធារណៈ ក្រសួងអប់រំ យុវជន និងកីឡា និងយន្តការផ្សព្វផ្សាយនានាផងដែរ។ ទន្ទឹមនឹងនេះ គណៈកម្មការរៀបចំការប្រឡង ក៏បានគូសបញ្ជាក់សម្គាល់ជូនបេក្ខជនជាប់ជាស្ថាពរ ចំពោះនីតិវិធីបន្តបន្ទាប់ពីការប្រកាសលទ្ធផល ដោយក្នុងរយៈពេល១ (មួយ) សប្តាហ៍ ត្រឹមថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ១៧ះ០០ ជាកំហិត បេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរត្រូវផ្តល់ការបញ្ជាក់ទទួលយកក្របខណ្ឌនៅទីកន្លែងការងារដែលបានជ្រើសរើស មកអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ តាមរយៈទូរស័ព្ទ /តេឡេក្រាម ០៨៩ ៨៣៩ ១៣៨ ។ ជាមួយគ្នានេះ បេក្ខជនដែលមិនអស់ចិត្តចំពោះលទ្ធផល និងមានបំណងស្នើសុំការពិនិត្យសន្លឹកកិច្ចការរបស់ខ្លួន អាចដាក់ជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ។

ក្រសួងមុខងារសាធារណៈ នឹងចេញសេចក្តីសម្រេចទទួលស្គាល់បេក្ខជនជាផ្លូវការ ដើម្បីបន្តនីតិវិធីនៃការរៀបចំការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា និងផ្តល់ក្របខណ្ឌស្របតាមលិខិតបទដ្ឋានជាធរមាន។ សូមជម្រាបជូនផងដែរថា បន្ទាប់ពីក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមបណ្តុះបណ្តាល ហើយករណីមានបេក្ខជនជាប់ជាស្ថាពរបោះបង់ក្របខណ្ឌ ក្រសួងអាចជ្រើសរើសយកបេក្ខជនជាប់បម្រុងដែលមានពិន្ទុខ្ពស់ជាងគេក្នុងខេត្ត ដើម្បីជំនួសបាន។ ការជ្រើសរើសជំនួសនេះ អាចអនុវត្តបានតែក្នុងរយៈពេល (២) សប្តាហ៍ បន្ទាប់ពីការបណ្តុះបណ្តាលចាប់ផ្តើមតែប៉ុណ្ណោះ។

ការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា ជាការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការតាមប្រព័ន្ធប្រឡងប្រជែងថ្មីដែលជាវិធានគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល អាណត្តិទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីធានាបាននូវការផ្តល់ឱកាសស្មើៗគ្នា និងពង្រីកឱកាសបន្ថែម ជូនដល់យុវជន និងសាធារណជន ក្នុងការចូលរួមប្រឡងប្រជែងក្លាយខ្លួនជាមន្ត្រីរាជការបម្រើប្រទេសជាតិ និងប្រជាជន ប្រកបដោយសមត្ថភាព និងមានវិជ្ជាជីវៈពិតប្រាកដ។ ការប្រឡងប្រជែងនេះដែរ មានការចូលរួមពីថ្នាក់ដឹកនាំអន្តរក្រសួង-ស្ថាប័ន អនុគណៈកម្មការជំនាញ និងអ្នកសារព័ត៌មាន ដើម្បីធ្វើជាសាក្សីក្នុងដំណើរការប្រឡងតាំងពីថ្ងៃចាប់ផ្តើម រហូតដល់ថ្ងៃបញ្ចប់ប្រកាសលទ្ធផល។

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការជាគ្រូបង្រៀនឱ្យបម្រើការក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដល់ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងក្រុមការងារទាំងអស់នៃក្រសួងមុខងារសាធារណៈ, ក្រសួងអប់រំ យុវជន និងកីឡា , ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, អង្គភាពប្រឆាំងអំពើពុករលួយ, សហភាពសហព័ន្ធយុវជនកម្ពុជា, តំណាងសាកលវិទ្យាល័យ, អ្នកសង្កេតការណ៍, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សាលាភូមិន្ទរដ្ឋបាល,អាជ្ញាធរមូលដ្ឋាន មន្ត្រីសុខាភិបាល និងអ្នកសារព័ត៌មាន ដែលបានចូលរួមជាចលករនាំឱ្យដំណើរការប្រឡងប្រជែងប្រព្រឹត្តទៅបានដោយជោគជ័យគួរជាទីមោទនៈ ហើយឆ្លើយតបជាមួយគោលការណ៍កែទម្រង់រដ្ឋបាលសាធារណៈ ដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា៕